ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ: ១៣៦៥ អ.ក
ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០
សាលក្រមលេខ: ៣៩ "ច"
ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង០៩ និង ០០ព្រឹក ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង នៃអយ្យការ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសវនាការ

**មេធាវី**

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] នួនពុទ្ធិ ឈ្មោះ [redacted] រីត ឈ្មោះ [redacted] សារឿន ឈ្មោះ [redacted] ជាន់ណា ឈ្មោះ [redacted] ជា និងឈ្មោះ [redacted] សុខណាង
លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] សុធាចារ្យ
លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] រតនា ឈ្មោះ [redacted]

**សេងហៀង**

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] គឹមហ៊ា
លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] គឹមហ៊ា

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៣៦៥ អក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ៖

១-ឈ្មោះ [redacted] **នួនពុទ្ធិ** ហៅពុធ ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ប៉ូវ៉ារី (រស់) ម្ដាយឈ្មោះ [redacted] ចំរើន (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ថ្ងៃឃុំខ្លួន០៧-០៨-២០)

២-ឈ្មោះ [redacted] **វីត** ហៅវីត ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted]រ៉ា (រស់) ម្ដាយឈ្មោះ [redacted] សុផល (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។ (ថ្ងៃឃុំខ្លួន០៧-០៨-២០)

៣-ឈ្មោះ [redacted]**សុធាចារ្យ** ហៅសត្យា ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្នភូមិក្ដីចាស់ សង្កាត់ព្រែកបាក់ខែង ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]បូរិន (រស់) ម្ដាយឈ្មោះ[redacted]ចាន់អៀង (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

៤-ឈ្មោះ [redacted]**សេងហៀង** ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] (រស់) ម្ដាយឈ្មោះ[redacted]គឹមស្រេង (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

៥-ឈ្មោះ [redacted] **រតនា** ហៅ ម៉ាប់ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] វិសុទ្ធ (រស់) ម្ដាយឈ្មោះ[redacted]រី (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

៦-ឈ្មោះ [redacted] **សារឿន** ហៅ តូច ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សឿន (រស់) ម្ដាយឈ្មោះ[redacted]អួន (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (គេចខ្លួន)

៧-ឈ្មោះ [redacted] **ជាន់ណា** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted]ហេង (រស់) ម្ដាយឈ្មោះ[redacted] សុគង់ (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (គេចខ្លួន)

៨-ឈ្មោះ [redacted]**ធា** ហៅឌុយ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted] ប្រុស (រស់) ម្ដាយឈ្មោះ[redacted]សារឿន (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (គេចខ្លួន)

៩-ឈ្មោះ [redacted]**គឹមហ៊ា** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted] គា (រស់) ម្ដាយឈ្មោះ [redacted] ស៊ុននី (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ឃាត់ខ្លួន)

១០-ឈ្មោះ [redacted] **សុខណាង** ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted]ស៊ុយ (រស់) ម្ដាយឈ្មោះ[redacted] ហួន (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (គេចខ្លួន)

ត្រូវជាប់ចោទពីបទៈ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហិង្សា** ប្រព្រឹត្តនៅភូមិរកាកោះ និងភូមិព្រែកថ្មី ឃុំព្រែកញ្ញាញ ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ និងនៅអំឡុងឆ្នាំ២០២០ បទបញ្ញត្តិតាម**មាត្រា៣៥៣** និង**មាត្រា៣៥៧** នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងឈ្មោះ [redacted] ឆៃហ៊ី ភេទប្រុស អាយុ៦០ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីលំនៅបច្ចុប្បន្ននៅភូមិលើ ឃុំព្រែកអញ្ញាញ ស្រុកមុខកំពូល ខេត្តកណ្ដាល។

-ជនរងគ្រោះឈ្មោះ [redacted]នី ភេទស្រី អាយុ៥៦ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរជាងដេរ ទីលំនៅបច្ចុប្បន្ននៅភូមិលើ ឃុំព្រែកអញ្ញាញ ស្រុកមុខកំពូល ខេត្តកណ្ដាល។

## ដំណាលរឿងហេតុមានដូចតទៅ៖

កាលអំឡុងឆ្នាំ២០២០ ជនសង្ស័យជាក្រុមលួចមានគ្នាចំនួន១០នាក់ មានឈ្មោះ [redacted] **សារឿន** ហៅ **តូច** ឈ្មោះ [redacted] **ដាន់ណា** ឈ្មោះ [redacted] ធា ហៅឌុយ ឈ្មោះ [redacted] រតនា ហៅម៉ាប់ ឈ្មោះ[redacted] **គឹមហ៊ា** ឈ្មោះ [redacted] **សំណាង** ឈ្មោះ [redacted] **សុធាចារ្យ** ហៅសត្យា ឈ្មោះ [redacted] **សេងហៀង** ឈ្មោះ [redacted] **នួនពុទ្ធិ** និង ឈ្មោះ [redacted] **វីត** តែងតែធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិពីប្រជាពលរដ្ឋជាអ្នកធ្វើដំណើរតាមដងផ្លូវជាច្រើនលើកច្រើនសារ ស្ថិតនៅចំណុចស្ពានទី១៣ នៅក្នុងភូមិព្រែកថ្មី ឃុំព្រែកអញ្ញាញ ស្រុកមុខកំពូល ខេត្តកណ្ដាល។ លុះដល់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៦ និង៣០នាទីព្រឹក ជនសង្ស័យមានគ្នា០៤នាក់ មានឈ្មោះ [redacted] សារឿន ហៅ តូច ឈ្មោះ [redacted] នួនពុទ្ធិ ឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា និងឈ្មោះ [redacted] វីត ហៅ វីត ជិះម៉ូតូពីរគ្រឿងបានធ្វើសកម្មភាពឆក់កាបូបប្រាក់ពីអ្នកដំណើរឈ្មោះ [redacted] ឆៃហ៊ី និងឈ្មោះ [redacted] នី នៅចំណុចភូមិរកាកោះ ឃុំព្រែកអញ្ញាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ហើយរហូតដល់ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ ទើបសមត្ថកិច្ចស្រាវជ្រាវចាប់បានឈ្មោះ [redacted] នួនពុទ្ធិ និងបន្តចាប់បានឈ្មោះ [redacted] វីត ហៅ វីត នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ

## សាលាដំបូងខេត្តកណ្ដាល

## យល់ឃើញថា

១.តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ឆាំហ៊ី និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ, ឈ្មោះ [redacted] រតនា ហៅ ម៉ាប់, ឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា, ឈ្មោះ [redacted] គឹមហ៊ា, ឈ្មោះ [redacted] សេងហៀង, ឈ្មោះ [redacted] វីត ព្រមទាំងចម្លើយ តទល់របស់ជនជាប់ចោទឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា ជាមួយនឹងជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ និងឈ្មោះ [redacted] វីត រួមទាំងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ បន្ថែមជាមួយនឹងតាមការពិនិត្យឯកសារនានានៅក្នុងសំណុំរឿង ឃើញថា តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល បានបើកការចោទប្រកាន់ទៅលើជនជាប់ចោទខាងលើ ពីបទ **លួចមានស្ថានទម្ងន់**



Scanned with CamScanner

**ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តិនៅភូមិរកាកោះ និងភូមិព្រែកថ្មី ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល គប្បីតុលាការធ្វើការពិចារណាអំពីអង្គហេតុនៃបទល្មើសនេះ ។

២.នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ៖

២.១.ជនជាប់ចោទទាំងប្រាំបីនាក់ឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ ភេទ ប្រុស អាយុ ២២ឆ្នាំ, ឈ្មោះ [redacted] រតនា ហៅ ម៉ាប់ ភេទ ប្រុស អាយុ ២៤ឆ្នាំ, ឈ្មោះ [redacted] សេងហៀង ភេទ ប្រុស អាយុ ២០ឆ្នាំ, ឈ្មោះ [redacted] សុជាចារ្យ ហៅ សត្យា ភេទ ប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ [redacted] សារឿន ហៅ តូច ភេទ ប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ [redacted] ធា ហៅ ឌុយ ភេទ ប្រុស អាយុ ២០ឆ្នាំ, ឈ្មោះ [redacted] គីមហ៊ា ភេទ ប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] សុខណាង ភេទ ប្រុស អាយុ ២១ឆ្នាំ គឺជានីតិជន(ជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅនៅក្នុងពេលប្រព្រឹត្តបទល្មើស) ដែលមានស្មារតី និង សមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើរបស់ខ្លួនចំពោះមុខច្បាប់ ពោលគឺជនជាប់ចោទអាចបង្ហាញថា ខ្លួនមានស្មារតីពេញលក្ខណៈគ្រប់គ្រាន់នៅក្នុងពេលប្រព្រឹត្តបទល្មើស ហើយអាចយល់ដឹងចំពោះអំពើល្មើសដែលខ្លួនបានប្រព្រឹត្ត ។

២.២.ជនជាប់ចោទឈ្មោះ [redacted] រីត ភេទ ប្រុស អាយុ ១៥ឆ្នាំ និងឈ្មោះ [redacted] ផាន់ណា ភេទ ប្រុស អាយុ ១៧ឆ្នាំ គឺជាអនីតិជន(ជនដែលមានអាយុក្រោម១៨ឆ្នាំនៅក្នុងពេលប្រព្រឹត្តបទល្មើស) ដែលពុំមានស្មារតី និង សមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើរបស់ខ្លួនចំពោះមុខច្បាប់ឡើយ គប្បីតុលាការផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទដែលជាអនីតិជនខាងលើ ។

៣.អំពើសត្យានុម័តរបស់ជនជាប់ចោទ៖

៣.១.តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ផៃហ៊ុ ភេទ ប្រុស អាយុ៦០ឆ្នាំ បានឆ្លើយនៅដំណាក់កាលអយ្យការថា កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ០៦ និង ៣០ នាទីព្រឹកក ខ្លួនបានជិះម៉ូតូឌុបប្រពន្ធទៅខេត្តកំពង់ចាម ទៅលេងបងប្អូន មកដល់ចំណុចកើតហេតុស្ថិតនៅភូមិកោះរកា ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ស្រាប់តែមានក្មេងស្ទាវពីរនាក់ ដោយជិះម៉ូតូមួយគ្រឿងម៉ាកឌ្រីម C125 បានធ្វើសកម្មភាពឆក់កាបូបប្រពន្ធខ្លួនដែលជិះពីក្រោយ ធ្វើឱ្យប្រពន្ធខ្លួនបានធ្លាក់ពីលើម៉ូតូ ចំណែកម៉ូតូខ្លួន និងម៉ូតូក្មេងស្ទាវនោះបានប៉ះដៃចង្កូតគ្នា ធ្វើឱ្យម៉ូតូដួលទាំងពីរ។ ពេលខ្លួនក្រោកឡើង បានឃើញក្មេងស្ទាវម្នាក់កំពុងតែលើកម៉ូតូវា ខ្លួនក៏ស្ទុះទៅចាប់អាវវាជាប់ ប៉ុន្តែពុំមានប្រជាពលរដ្ឋណាមួយជួយខ្លួនទេ ពីព្រោះខ្លួនមិនបានស្រែកថា ចោរៗ ក្រោយមកក្មេងស្ទាវនោះបានរើបំរាស់ចេញពីដៃខ្លួន ហើយរត់គេចខ្លួនបាត់បន្សល់តែម៉ូតូដែលវាធ្វើសកម្មភាព។ មួយសន្ទុះក្រោយមក បានឃើញសមត្ថកិច្ចមកដល់ បានយកម៉ូតូដែលធ្វើសកម្មភាពនោះ និងហៅខ្លួនទៅសាលាស្រុកមុខកំពូលដើម្បីសួរនាំ រួចខ្លួនបានដាក់ពាក្យបណ្តឹងតែម្តង។ ខ្លួន និងប្រពន្ធមិនមានបាត់បង់ទ្រព្យសម្បត្តិនោះទេ តែប្រពន្ធខ្លួនរបួសដោយត្រូវក្បាលជង្គង់ មុខ ត្រគាក និងខូចម៉ូតូ។ ប្រពន្ធខ្លួនបានសម្រាកព្យាបាលនៅមន្ទីរពេទ្យកម្ពុជា-គុយវ៉ែត ដោយចំណាយអស់ថវិកាប្រហែលជា ៦០០$ និងសព្វថ្ងៃកំពុងតែទិញថ្នាំលាបរាល់ថ្ងៃ។ ខ្លួនសំណូមពរមិនទាមទារសំណងទេ និងសុំដកពាក្យបណ្តឹង ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ សុំឱ្យតុលាការធ្វើតាមនីតិវិធី។

៣.២.ជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ បានឆ្លើយសារភាពនៅក្នុងពេលសវនាការដេញដោលចំពោះមុខថា ខ្លួនបានដឹងពីបទចោទប្រកាន់រួចហើយ។ មុខដំបូងខ្លួនធ្លាប់ធ្វើសកម្មភាពលួចបានម្តង ដោយលួចបានទូរស័ព្ទលក់បានចំនួន ៨០$ ។ នៅក្នុងថ្ងៃកើតហេតុ ខ្លួនធ្វើសកម្មភាពដោយមានគ្នាពីរនាក់ ជិះម៉ូតូពីរ



Scanned with CamScanner

គ្រឿង ពីរនាក់ប្រុសតូច និងឈ្មោះ សារឿន ។ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ធ្វើសកម្មភាពមានគ្នា ៤នាក់ ជិះម៉ូតូ២គ្រឿងមានឈ្មោះ សារឿន ឈ្មោះ វីត ឈ្មោះ សុធាចារ្យ និងខ្លួន ពេលនោះជិះតាមផ្លូវដើររក ។ ពេលដែលខ្លួនធ្វើសកម្មភាព ក៏បានប៉ះដៃចង្កូតម៉ូតូ រួចក៏ដួលម៉ូតូ រីឯខ្លួនក៏រត់គេចខ្លួនតែម្តង។ សមត្ថកិច្ចចាប់ខ្លួនបានប្រហែលជា កន្លះខែក្រោយថ្ងៃកើតហេតុ ។ ខ្លួនធ្លាប់ឆក់បានម្តង ឥឡូវខ្លួនដឹងខុសហើយ។ អ្នកដែលចូលរួមធ្វើសកម្មភាពលួចជាមួយខ្លួន មានឈ្មោះ [redacted] វីត ហៅ វីត ឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា ឈ្មោះ តូច និងរូបខ្លួន មកលួចជាមួយគ្នា លុះខ្លួនមិនប្រុងប្រយ័ត្នក៏ដួលតែម្តង។ ខ្លួនថា ស្គាល់នោះ គឺមានន័យថា ខ្លួនធ្លាប់ដើរលេងនិងហូបចុកជាមួយគ្នា មិនមែនលួចនោះទេ។ ឈ្មោះ [redacted] ធា ធ្លាប់និយាយថា ខ្លួនឆក់ ដោយឈ្មោះ [redacted] ធា ដើរជាមួយឈ្មោះ [redacted] សេងហៀង ឈ្មោះ [redacted] វីត ។ ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅសមត្ថកិច្ចទុកជាបានការដែល។ ពួកខ្លួនឧស្សាហ៍ទៅលេងបាល់ជាមួយគ្នា។ ក្នុងចំណោម ១០នាក់ខាងលើ ជាមិត្តភក្តិរបស់ខ្លួន ដោយឈ្មោះ [redacted] សុធាចារ្យ ឈ្មោះ [redacted] វីត ឈ្មោះ [redacted] សារឿន និងខ្លួន នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ មិនបានលួចទេ ពីព្រោះដួលម៉ូតូ។ ពេលលួច គឺខ្លួន និងឈ្មោះ សារឿន ជាអ្នកលួច ដោយជិះម៉ូតូសង់ទ្រីម ពណ៌ក្រហម។ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ខ្លួនធ្វើសកម្មភាពមានគ្នា ៤នាក់ ដូចបានរៀបរាប់ខាងលើ ដោយបួននាក់នោះ ក៏បានដឹងថា ទៅលួចដែរ ។ រាល់ពេលឆក់ គឺខ្លួនជាអ្នកឆក់ ដោយម៉ូតូផ្សេងជិះតាមក្រោយ ខ្លួនបានពិភាក្សាគ្នាមុនលួច។ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ក្រៅពីឈ្មោះដែលខ្លួនបានបញ្ជាក់ខាងលើ គឺគ្មានអ្នកផ្សេងទេ។

៣.៣.ជនជាប់ចោទឈ្មោះ [redacted] វីត ហៅ វីត បានឆ្លើយសារភាពនៅក្នុងពេលសវនាការដេញដោលចំពោះមុខថា នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ មានឈ្មោះ [redacted] សារឿន ហៅតូច ឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ ឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា និងខ្លួន ។ ខ្លួនជិះចេញរកស៊ី(លួច) ពីព្រែកសំរោង ដល់បាក់ខែង ដោយពេលនោះ ខ្លួន ជិះជាមួយឈ្មោះ [redacted] សុធាចារ្យ ហើយចូលផ្ទះ សុធាចារ្យ ។ ឈ្មោះ [redacted] ពុទ្ធិ ហៅ ពុធ ប្រាប់ថា នៅមុខមានកាបូប ហើយប្រាប់ថា ហែងមកឱ្យលឿនមក ខ្លួនក៏ប្រាប់ថា បន្តិចទៀតទៅហើយ។ ដល់មុខក៏និយាយថា នៅមុខមានកាបូបទៀត ក្នុងគោលបំណងដើររកជាមួយគ្នា។ ក្រៅពីបីនាក់ខាងលើខ្លួនមិនដឹងថា ពួកខាងលើធ្លាប់ឆក់ទេ ដោយពួកខ្លួននៅភូមិជាមួយគ្នា។ ខ្លួនដេកផ្ទះឈ្មោះ សុធាចារ្យ ពីមុនខ្លួនធ្លាប់ឆក់ជាមួយឈ្មោះ សុធាចារ្យ ក្រោយមកមុនធ្លាប់ទេ។ ឈ្មោះ ពុទ្ធិ ឆ្លើយដាក់ខ្លួន និងឈ្មោះ ចារ្យ ទើបគេចាប់ខ្លួន ។ ឈ្មោះ សារឿន ហៅ តូច ស្និតជាមួយឈ្មោះ ពុទ្ធិ ជាងគេ ។ ពីដើមមកខ្លួនធ្លាប់ដើរលួចគេដែរ ដោយធ្លាប់លួចជាមួយឈ្មោះ សុធាចារ្យ នៅឆ្នាំ២០២០។ សមត្ថកិច្ចចាប់ខ្លួននៅកន្លែងលេងបាល់។

៣.៤.ជនជាប់ចោទឈ្មោះ [redacted] គឹមហ៊ា បានឆ្លើយសារភាពនៅក្នុងពេលសវនាការដេញដោលចំពោះមុខថា ខ្លួនមិនធ្លាប់ដឹងទេ ។ ខ្លួនស្គាល់គ្នាតាមរយៈលេងបាល់ជាមួយគ្នា ដោយខ្លួនមិនដែលលួចទេ។ ខ្លួនមិនដឹងទេ ហើយខ្លួនក៏មិនធ្លាប់មានគំនុំអ្វីជាមួយពួកគេដែរ។ ខ្លួនធ្លាប់លេងបាល់ជាមួយឈ្មោះ ពុទ្ធិ តែមិនជិតស្និតទេ ដោយខ្លួនមិនធ្លាប់ធ្វើសកម្មភាពជាមួយឈ្មោះ ពុទ្ធិ ឡើយ ដោយជារៀងរាល់ថ្ងៃ ខ្លួនតែងតែទៅជួយលក់ត្រីប៉ាម៉ាក់របស់ខ្លួន បន្ទាប់ពីទំនេរមិនចូលរៀននៅសាលា(សាលាបិទ) ។

៣.៥.ជនជាប់ចោទឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា បានឆ្លើយសារភាពនៅក្នុងពេលសវនាការដេញដោលចំពោះមុខថា ខ្លួនបានដឹងពីបទចោទប្រកាន់រួចហើយ ។ ខ្លួនធ្លាប់ឱ្យម៉ូតូគេខ្ចី ដោយខ្លួនអត់ដែលធ្វើសកម្មភាពឆក់ទេ បើគេចង្អុលថា ខ្លួនឆក់(លួច) ខ្លួនមិនទទួលស្គាល់ឡើយ ពីព្រោះខ្លួនអត់ដែលបានធ្វើ



Scanned with CamScanner

សកម្មភាពបែបនោះឡើយ។ ខ្លួនអត់បានធ្វើសកម្មភាពលួចទេ។ ម៉ូតូរបស់ខ្លួនដែលជិះទៅរៀន មានតែមួយគ្រឿងទេ គឺម៉ាក Scopy ។ ខ្លួនមិនបានធ្វើសកម្មភាពលួចដូចការចោទប្រកាន់ទេ ។

៣.៦.ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ ម៉ាប់ បានឆ្លើយសារភាពនៅក្នុងពេលសវនាការដេញដោលចំពោះមុខថា ខ្លួនអត់បានធ្វើអ្វីទេ ប៉ុន្តែខ្លួនស្គាល់អ្នកទាំងអស់គ្នា ដោយខ្លួនធ្វើការនៅភ្នំពេញ ពេលនៅស្រុកបានជួបគ្នា ដោយធ្លាប់ដើរលេងជាមួយគ្នា។ ខ្លួនអត់ដែលធ្វើសកម្មភាពឆក់(លួច) នោះទេ ។ ឈ្មោះ តូចនិងឈ្មោះ ពុទ្ធិ បានធ្វើសកម្មភាពហើយដួលម៉ូតូដោយខ្លួនដឹងព័ត៌មាននេះ តាមរយៈឈ្មោះ ណាខា ប្រាប់ថា ឈ្មោះ តូច ពុទ្ធិ ឆក់គេដួលម៉ូតូ។ កន្លងមក ខ្លួនអត់ដែលដើរជាមួយគ្នាទេ ដោយខ្លួនធ្លាប់មានទំនាស់ជាមួយគ្នាពីមុនមក ដោយខ្លួនជាជាងមេកានិក។ ខ្លួនមិនធ្លាប់ស្គាល់គ្នាស្និតស្នាលទេ ដោយខ្លួនគ្រាន់តែមានទំនាស់ទំនងធម្មតាជាមួយគ្នាតែប៉ុណ្ណោះ ដោយខ្លួនធ្លាប់ទៅលេងកំពត់ជាមួយឈ្មោះ តូច និងឈ្មោះ ឌុយ បានម្តង ដោយខ្លួនរាប់អានគ្នាធម្មតា ស្គាល់គ្នានៅតារាងបាល់។ ខ្លួនមានផ្ទះនៅភ្នំពេញផង និងនៅស្រុកផង ដោយយូរៗខ្លួនទៅលេងផ្ទះនៅព្រែកអញ្ចាញម្តង ។ ខ្លួនពិតជាមិនបានចូលរួមលួច និងដឹងរឿងលួចនោះទេ ។

*តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ឆាំហ៊ី និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ, ឈ្មោះ [redacted] រតនា ហៅ ម៉ាប់, ឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា, ឈ្មោះ [redacted] វីត ហៅ វីត និង ឈ្មោះ [redacted] គឹមហ៊ា ព្រមទាំងចម្លើយតទល់របស់ជនជាប់ចោទឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា ជាមួយនឹងជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ និងឈ្មោះ [redacted] វីត ហៅ វីត រួមទាំងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ បន្ថែមជាមួយនឹងការពិនិត្យឯកសារនានានៅក្នុងសំណុំរឿង អាចឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ ភេទ ប្រុស អាយុ ២២ឆ្នាំ ឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា ភេទ ប្រុស អាយុ ១៩ឆ្នាំ ឈ្មោះ [redacted] សារឿន ហៅ តូច ភេទ ប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] វីត ហៅ វីត ភេទ ប្រុស អាយុ ១៥ឆ្នាំ គឺពិតជាបានប្រព្រឹត្តបទល្មើសលួចមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់អំពើហិង្សា ប្រាកដមែន ទោះបីជាជនជាប់ចោទឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា បានព្យាយាមឆ្លើយបដិសេធន៍នៅពេលសវនាការដេញដោលចំពោះមុខថា ខ្លួនមិនបានដឹង និងមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការក៏ដោយ ប៉ុន្តែតុលាការយល់ឃើញថា ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា ដែលបានឆ្លើយនៅចំពោះមុខអង្គសវនាការ គ្រាន់តែជាចម្លើយភូតកុហកដើម្បីគេចវេសពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តខុសទៅនឹងបញ្ញត្តិច្បាប់តែប៉ុណ្ណោះ។ ពីព្រោះជាក់ស្តែងណាស់ គឺជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ និងឈ្មោះ [redacted] វីត ហៅ វីត បានឆ្លើយយ៉ាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាថា ពួកខ្លួនពិតជាបានធ្វើសកម្មភាពលួចដោយជិះម៉ូតូពីរគ្រឿង មានគ្នា ៤នាក់ រួមមានឈ្មោះ [redacted] វីត ហៅ វីត ជិះម៉ូតូជាមួយឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា រីឯឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ ជិះម៉ូតូជាមួយឈ្មោះ [redacted] សារឿន ហៅ តូច ចេញពីព្រែកសំរោងទៅបាក់ខែង ក៏បានឃើញជនរងគ្រោះកំពុងតែជិះម៉ូតូ ពេលនោះពួកខ្លួនក៏បានធ្វើសកម្មភាពលួចតែម្តង ដោយឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា ជិះជាមួយឈ្មោះ [redacted] វីត ហៅ វីត ពីក្រោយពួកខ្លួនកាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ។*

*ដោយឡែកជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ ម៉ាប់ ភេទ ប្រុស អាយុ ២៤ឆ្នាំ, ឈ្មោះ [redacted] គឹមហ៊ា ភេទ ប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] សេងហៀង ភេទ ប្រុស អាយុ ២០ឆ្នាំ, ឈ្មោះ [redacted] ជាន់ណា ភេទ ប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ធា ហៅ ឌុយ ភេទ ប្រុស អាយុ ២០ឆ្នាំ និងឈ្មោះ [redacted] សុខណាង ភេទ ប្រុស*

អាយុ ២១ឆ្នាំ គឺមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះឡើយ ពីព្រោះនៅក្នុងពេលសវនាការពិភាក្សាដេញដោលចំពោះមុខ គឺជនជាប់ចោទឈ្មោះ [redacted] វីត ហៅ វីត និងឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ ដែលមានវត្តមាននៅពេលសវនាការ បានបញ្ជាក់យ៉ាងច្បាស់លាស់ថា ជនជាប់ចោទផ្សេងទៀតមិនបានប្រព្រឹត្តអំពើលួចនោះទេ ដោយនៅពេលលួចនោះ គឺមានតែឈ្មោះ [redacted] សុជាចារ្យ ហៅសត្យា ជិះម៉ូតូជាមួយឈ្មោះ [redacted] វីត ហៅ វីត រីឯឈ្មោះ [redacted] នួនពុទ្ធិ ជិះម៉ូតូជាមួយឈ្មោះ [redacted] សារឿន ហៅ តូច ហើយពួកខ្លួនស្គាល់ជនជាប់ចោទខាងលើ ពីព្រោះតែជនជាប់ចោទជាអ្នកភូមិរស់នៅជាមួយគ្នា និងធ្លាប់លេងបាល់នៅសាលាជាមួយគ្នាតែប៉ុណ្ណោះ។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ និងឈ្មោះ [redacted] វីត ហៅ វីត គឺមានភាពស៊ីសង្វាក់គ្នានឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ ម៉ាប់ និងឈ្មោះ [redacted] គឹមហ៊ា ដែលបានឆ្លើយថា ខ្លួនមិនមានការពាក់ព័ន្ធនៅក្នុងរឿងលួចនេះនោះឡើយ ដោយពួកខ្លួនគ្រាន់តែស្គាល់គ្នាតាមរយៈលេងបាល់ជាមួយគ្នា និងរស់នៅជាមួយគ្នាតែប៉ុណ្ណោះ ដូច្នេះគប្បីតុលាការសម្រេចលើកលែងការចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ ម៉ាប់ ភេទ ប្រុស អាយុ ២៤ឆ្នាំ, ឈ្មោះ [redacted] គឹមហ៊ា ភេទ ប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] សេងហៀង ភេទ ប្រុស អាយុ ២០ឆ្នាំ, ឈ្មោះ [redacted] ជាន់ណា ភេទ ប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ជា ហៅ ឌុយ ភេទ ប្រុស អាយុ ២០ឆ្នាំ និងឈ្មោះ [redacted] សុខណាង ភេទ ប្រុស អាយុ ២១ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់អំពើហិង្សា ប្រព្រឹត្តនៅភូមិកាកោះ និងភូមិព្រៃកថ្មី ឃុំព្រៃកអញ្ចាញ ស្រុកមុខ កំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ និងកាលពីអំឡុងឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤.ទំនាក់ទំនងហេតុបច្ច័យនៃទង្វើរបស់ជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ ភេទ ប្រុស អាយុ ២២ឆ្នាំ, ឈ្មោះ [redacted] សុជាចារ្យ ហៅ សត្យា ភេទ ប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ [redacted] សារឿន ហៅ តូច ភេទ ប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] វីត ភេទ ប្រុស អាយុ ១៥ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើខុសពីច្បាប់របស់សង្គមពិតមែន ពោលគឺ ពួកជនជាប់ចោទទាំងអស់គ្នា បានធ្វើសកម្មភាពជាក្រុមក្នុងការលួចយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ថែមទាំងបណ្ដាលឱ្យជនរងគ្រោះធ្លាក់ពីលើម៉ូតូបង្កឱ្យមានរបួសដល់រាងកាយទៀតផងដែលអំពើនេះ គឺស៊ីសង្វាក់គ្នាទៅនឹងព្យសនកម្មរបស់ជនរងគ្រោះ ព្រមទាំងចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានបញ្ជាក់ថា ប្រពន្ធរបស់ខ្លួនបានធ្លាក់ពីលើម៉ូតូដោយសារតែជនជាប់ចោទទាំងពីរនាក់ទាញកាបូបបណ្ដាលឱ្យរងរបួសចូលព្យាបាលនៅមន្ទីរពេទ្យចំណាយអស់ប្រាក់ចំនួន៦០០$ ដែលសកម្មភាពនេះជាហេតុនាំឱ្យមានទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។

៥.ធាតុអត្តនោម័តរបស់ជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ ភេទ ប្រុស អាយុ ២២ឆ្នាំ, ឈ្មោះ [redacted] សុជាចារ្យ ហៅ សត្យា ភេទ ប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ [redacted] សារឿន ហៅ តូច ភេទ ប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] វីត ភេទ ប្រុស អាយុ ១៥ឆ្នាំ គឺមានស្មារតី មានការយល់ដឹង ព្រមទាំងមានវិចារណញ្ញាណគ្រប់គ្រាន់ដែលអាចវិនិច្ឆ័យបានថា អំពើដែលខ្លួនប្រព្រឹត្តិ គឺជាអំពើមិនល្អដែលសង្គមមិនទទួលស្គាល់ ហើយល្មើសទៅនឹងច្បាប់របស់ប្រទេសថែមទៀតផង។ ទោះបីដឹងថាយ៉ាងនេះក៏ដោយ ក៏ជនជាប់នៅតែមានឆន្ទៈក្នុងការប្រព្រឹត្តិបទល្មើសដែលច្បាប់បានហាមឃាត់ដដែល ពោលគឺ ជនជាប់ចោទមានចេតនាយ៉ាងពិតប្រាកដក្នុងការដកហូត (លួច) យកទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ពីព្រោះពួកគេតែងតែបបួលគ្នាជិះម៉ូតូធ្វើសកម្មភាពលួចនៅលើផ្លូវចំពោះជនរងគ្រោះណាដែលមានទ្រព្យសម្បត្តិ និងមានកាបូបមានដាក់វត្ថុមានតម្លៃ



Scanned with CamScanner

ជាដើម ដែលជនជាប់ចោទបានដឹងយ៉ាងច្បាស់លាស់ថា ទង្វើដែលខ្លួនបានប្រព្រឹត្តនេះ គឺជាទង្វើខុសច្បាប់ ហើយច្បាប់ចាត់ទុកអំពើនេះថា ជាបទល្មើស **លួចមានស្ថានទម្ងន់ទោសប្រព្រឹត្តដោយការប្រើប្រាស់អំពើហិង្សា** តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៦.អំពើរបស់ជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ ភេទ ប្រុស អាយុ ២២ឆ្នាំ, ឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា ភេទ ប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ [redacted] សារឿន ហៅ តូច ភេទ ប្រុស អាយុ ១៩ឆ្នាំ និង ឈ្មោះ [redacted] វីត ភេទ ប្រុស អាយុ ១៥ឆ្នាំ គឺជាអំពើមួយដែលធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់សន្តិសុខសង្គមពិតប្រាកដមែន ហើយអំពើរបស់ជនជាប់ចោទខាងលើ ដែលបានប្រព្រឹត្តនៅភូមិរកាកោះ និងភូមិព្រែកថ្មី ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០២០ និងនៅអំឡុងឆ្នាំ២០២០ ត្រូវបានច្បាប់កំណត់ថា ជាបទល្មើស លួច**មានស្ថានទម្ងន់ទោសប្រព្រឹត្តដោយការប្រើប្រាស់អំពើហិង្សា** តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៧.មានធាតុផ្សំនៃបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ ភេទ ប្រុស អាយុ ២២ឆ្នាំ, ឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា ភេទ ប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ [redacted] សារឿន ហៅ តូច ភេទ ប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] វីត ភេទ ប្រុស អាយុ ១៥ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោសប្រព្រឹត្តដោយការប្រើប្រាស់អំពើហិង្សា** ប្រព្រឹត្តនៅភូមិរកាកោះ និងភូមិព្រែកថ្មី ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ និងនៅអំឡុងឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៨.ការសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការថា ផ្អែកតាមអង្គហេតុ និង ចម្លើយផ្ទាល់របស់ជនជាប់ចោទព្រមទាំងភស្តុតាងផ្សេងៗ គឺតំណាងអយ្យការ សូមឱ្យតុលាការជំនុំជំរះ ធ្វើការជំនុំជំរះទៅតាមអង្គហេតុ និងអង្គច្បាប់ ហើយតម្កល់ការចោទប្រកាន់ទុកជាបានការដដែល ។

៩.លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ ឈ្មោះ [redacted] វីត ហៅវីត ឈ្មោះ [redacted] សារឿន ហៅតូច ឈ្មោះ [redacted] ជាន់ណា ឈ្មោះ [redacted] ធា ហៅឌុយ និងឈ្មោះ [redacted] សុខណាង បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] វីត ហៅ វីត បានឆ្លើយសារភាពអំពីទង្វើរបស់ខ្លួន និងបក្សពួករបស់ខ្លួនដោយគ្មានការលាក់បាំងអ្វីឡើយដែលជាហេតុនាំឱ្យការជម្រះក្តីរបស់តុលាការមានភាពងាយស្រួលក្នុងការរកមុខរកជនល្មើសដទៃទៀត និងកូនក្តីរបស់ខ្លួនជាអនីតិជនផង សូមឱ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីឈ្មោះ [redacted] វីត ហៅវីត ជាអប្បរមានៃទោស។ ផ្ទុយពីនេះ ចំពោះកូនក្តីរបស់ខ្លួនផ្សេងទៀត សូមឱ្យតុលាការជួយបន្ធូរបន្ថយដល់ដល់កូនក្តីរបស់ខ្លួនផង។

១០.លោកស្រី យឹម ថាវី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ ម៉ាប់ និងឈ្មោះ [redacted] សេងហៀង បានធ្វើសេចក្តីសន្និដ្ឋានថា នៅក្នុងរឿងនេះ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] រតនា ហៅ ម៉ាប់ និង ឈ្មោះ [redacted] សេងហៀង គឺមិនមានការជាប់ពាក់ព័ន្ធនឹងបទល្មើសខាងលើដែលតំណាងអយ្យការបានចោទប្រកាន់នោះទេ ដូច្នេះស្នើសុំឱ្យតុលាការមេត្តាលើកលែងបទចោទប្រកាន់ដល់កូនក្តីរបស់ខ្លួនផង។

១១.លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុធាចារ្យ បានធ្វើសេចក្តីសន្និដ្ឋានថា នៅក្នុងរឿងនេះ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា មិនមានការជាប់ពាក់ព័ន្ធនឹងរឿងក្តីនោះទេ ស្នើសុំឱ្យតុលាការមេត្តាលើកលែងការចោទប្រកាន់លើកូនក្តីខ្លួនផង។



Scanned with CamScanner

១២.លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] គឹមហ៊ា បានធ្វើសេចក្តីសន្និដ្ឋានថា នៅក្នុងរឿងនេះ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] គឹមហ៊ា មិនមានការជាប់ពាក់ព័ន្ធនៅក្នុងរឿងក្តីនោះទេ ហើយកូនក្តីរបស់ខ្លួនក៏មិនបានប្រព្រឹត្តដូចការចោទប្រកាន់ដែរ ស្នើសុំឱ្យតុលាការមេត្តាលើកលែងបទចោទប្រកាន់មកលើរូបកូនក្តីរបស់ខ្លួនផង។

១៣.សំណូមពរចុងក្រោយជនជាប់ចោទ៖

១៣.១.ជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ បានសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ពីព្រោះខ្លួនដឹងកំហុសហើយ។

១៣.២.ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ ម៉ាប់ សំណូមពរឱ្យតុលាការលើកលែងទោសឱ្យខ្លួនផង ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

១៣.៣.ជនជាប់ចោទឈ្មោះ [redacted] សុជាចារ្យ ហៅ សត្យា សំណូមពរឱ្យតុលាការលើកលែងទោសឱ្យខ្លួនផង ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

១៣.៤.ជនជាប់ចោទឈ្មោះ [redacted] វីត ហៅ វីត បានសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ពីព្រោះខ្លួនដឹងកំហុសហើយ។

១៣.៥.ជនជាប់ចោទឈ្មោះ [redacted] គឹមហ៊ា សំណូមពរឱ្យតុលាការលើកលែងទោសឱ្យខ្លួនផង ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

១៤.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆាំហ៊ី បានដកពាក្យបណ្តឹងទៅលើជនជាប់ចោទខាងលើ និងមិនធ្វើការទាមទារសំណងការខូចខាតទៅលើជនជាប់ចោទឡើយ គប្បីតុលាការមិនធ្វើការពិចារណានៅក្នុងករណីនេះទេ។

១៥.វត្ថុចាប់យករួមមាន៖

១៥.១.ម៉ូតូ ១គ្រឿង ម៉ាក Honda Dream C125 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AA-5116 ដែលជាមធ្យោបាយសម្រួលដល់ការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ។

១៥.២.ខ្សែ ក ច្រវ៉ាក់ឆាប ចំនួន ០១ (មួយ) ខ្សែ ធ្វើអំពីស្ពាន់, កាបូបលុយចំនួន ០១(មួយ), នាឡិកាដៃចំនួន ០១(មួយ) និងថ្នាំជំនួយខួរក្បាលចំនួន ០១កំប៉ុង (១៣គ្រាប់) គប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ ។

## ហេតុដូច្នេះ សាលាដំបូងខេត្តកណ្តាល

## វិនិច្ឆ័យសេចក្តី

១.ឱ្យជនជាប់ចោទឈ្មោះ [redacted] **រតនា ហៅ ម៉ាប់** ភេទ ប្រុស អាយុ ២៤ឆ្នាំ(មានអត្តសញ្ញាណដូចខាងលើ), ឈ្មោះ [redacted]**ដាន់ណា** ភេទ ប្រុស អាយុ ១៧ឆ្នាំ(មានអត្តសញ្ញាណដូចខាងលើ), ឈ្មោះ [redacted]**ធា ហៅ ឌុយ** ភេទ ប្រុស អាយុ ២០ឆ្នាំ(មានអត្តសញ្ញាណដូចខាងលើ), ឈ្មោះ [redacted] **សុខណាង** ភេទ ប្រុស អាយុ ២១ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ), ឈ្មោះ [redacted] **សេងហៀង** ភេទ ប្រុស អាយុ២០ឆ្នាំ(មានអត្តសញ្ញាណដូចខាងលើ) និងឈ្មោះ [redacted]**គឹមហ៊ា** ភេទ ប្រុស អាយុ ១៨ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) **រួចផុតពីបទចោទប្រកាន់** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តឡើងនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ស្ថិតនៅភូមិរកាកោះ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល និងនៅអំឡុងឆ្នាំ២០២០ ស្ថិតនៅក្នុងភូមិព្រែកថ្មី ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.ផ្តន្ទាទោសជនជាប់ចោទដែលមានឈ្មោះដូចខាងក្រោម៖



Scanned with CamScanner

ក.ឈ្មោះ [redacted] វីត ហៅ វីត ភេទ ប្រុស អាយុ ១៥ឆ្នាំ(មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ចំនួន ១(មួយ)ឆ្នាំ ៦(ប្រាំមួយ)ខែ ។

ខ.ឈ្មោះ [redacted] **នួនពុទ្ធិ ហៅ ពុធ** ភេទ ប្រុស អាយុ ២២ឆ្នាំ(មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ចំនួន ៣(បី)ឆ្នាំ ។

គ.ឈ្មោះ [redacted] **សុធាចារ្យ ហៅ សត្យា** ភេទ ប្រុស អាយុ ១៩ឆ្នាំ(មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ចំនួន ៣(បី)ឆ្នាំ និងបង្គាប់ឱ្យចាប់ខ្លួន ។

ឃ.ឈ្មោះ [redacted] **សារឿន ហៅ តូច** ភេទ ប្រុស អាយុ ១៩ឆ្នាំ(មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ចំនួន ៣(បី)ឆ្នាំ និងបង្គាប់ឱ្យចាប់ខ្លួន ។

ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តឡើងនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ស្ថិតនៅភូមិរការកោះ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល និងនៅអំឡុងឆ្នាំ២០២០ ស្ថិតនៅក្នុងភូមិព្រែកថ្មី ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣.ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទ៖

៣.១.ឈ្មោះ [redacted] **សុធាចារ្យ** ហៅ សត្យា ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នភូមិក្តិចាស់ សង្កាត់ព្រែកបាក់ខែង ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] បូរិន (រស់) ម្តាយឈ្មោះ [redacted] ចាន់អៀង (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

៣.២.ឈ្មោះ [redacted] **សារឿន** ហៅ តូច ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សឿន (រស់) ម្តាយឈ្មោះ [redacted] អូន (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

៤.ចេញដីកាបញ្ឈប់ចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] **ជាន់ណា** ភេទ ប្រុស អាយុ ១៧ឆ្នាំ(មានអត្តសញ្ញាណដូចខាងលើ), ឈ្មោះ [redacted] **ធា ហៅ ឌុយ** ភេទ ប្រុស អាយុ ២០ឆ្នាំ(មានអត្តសញ្ញាណដូចខាងលើ) និងឈ្មោះ [redacted] **សុខណាង** ភេទ ប្រុស អាយុ ២១ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តឡើងនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ស្ថិតនៅភូមិរការកោះ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល និងនៅអំឡុងឆ្នាំ២០២០ ស្ថិតនៅក្នុងភូមិព្រែកថ្មី ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៥.បង្គាប់ឱ្យប្រធានពន្ធនាគារខេត្តកណ្តាល ដោះលែងជនជាប់ចោទឈ្មោះ [redacted] **គឹមហ៊ា** ភេទ ប្រុស អាយុ ១៨ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ប្រសិនបើឈ្មោះនេះ មិនត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទេ។

៦.វត្ថុតាងរួមមាន៖

៦.១.ម៉ូតូ ១គ្រឿង ម៉ាកHonda DreamC125 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AA-5116 សម្រេចរឹបអូសជាសម្បត្តិរដ្ឋ ។



Scanned with CamScanner

៦.២.ខ្សែ ក ច្រវ៉ាក់ឆាប ចំនួន ០១ (មួយ) ខ្សែ ធ្វើអំពីស្ពាន់, កាបូបលុយចំនួន ០១(មួយ), នាឡិកាដៃ ចំនួន ០១(មួយ) និងថ្នាំជំនួយខួរក្បាលចំនួន ០១កំប៉ុង (១៣គ្រាប់) សម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] នួនពុទ្ធិ ហៅ ពុធ, ឈ្មោះ [redacted] វីត ហៅ វីត, ឈ្មោះ [redacted] សុធាចារ្យ ហៅ សត្យា, ឈ្មោះ [redacted] រតនា ហៅ ម៉ាប់ និងឈ្មោះ [redacted] គឹមហ៊ា ដោយកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆៃហ៊ី រួមទាំងជនជាប់ចោទឈ្មោះ [redacted] សេងហៀង, ឈ្មោះ [redacted] សារឿន ហៅ តូច, ឈ្មោះ [redacted]ផាន់ណា, ឈ្មោះ [redacted] ធា ហៅ ឌុយ និងឈ្មោះ [redacted] សុខណាង ។

*ទុកសិទ្ធិឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៥រោច ខែផល្គុន ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

កណ្ដាល ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

[redacted]



Scanned with CamScanner